ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...២៤៤....អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ឆ្វៀលដីទំហំ៤៨ហិកតា៥៩អា៦៣សង់ទីអា ស្ថិតក្នុងភូមិអូរស្ពាន សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ចេញពីផលប៉ះពាល់ជាមួយសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហួរ លីង (ខេមបូឌា) អ៊ីនធើណេសិនណាល អ៊ិនសឺរេន ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និងប្រទានកម្មជាកម្មសិទ្ធិជូនឈ្មោះ ម៉ី កែវមរកត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៨០៦/៣៣៧ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបទបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ឆ្វៀលដីទំហំ៤៨ហិកតា៥៩អា៦៣សង់ទីអា ស្ថិតក្នុងភូមិអូរស្ពាន សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ដូចមានផែនទីបង្ហាញទីតាំង និងចំណុចនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យ ចេញពីផលប៉ះពាល់ជាមួយសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហួរ លីង (ខេមបូឌា) អ៊ីនធើណេសិនណល អ៊ិនស៊ីវេន ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ។

**មាត្រា ២.-**

ផ្តល់សិទ្ធិជាកម្មសិទ្ធិលើផ្ទៃដីទំហំ៤៨ហិកតា៥៩អា៦៣សង់ទីអា ស្ថិតក្នុងភូមិអូរស្ពាន សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ជូនឈ្មោះ ម៉ី កែវមរកត។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃពុធ ១១កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**អន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ២៤៨ អនក្រ.បក ចុះថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ២០២១

ផែនទីបង្ហាញទីតាំងដីស្នើសុំកាត់ឆ្វៀលចេញពីតម្រូវព្រៃឈើឆ្នាំ២០០២ និងផលប៉ះពាល់ជាមួយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ហួរ លីង (ខេមបូឌា) អ៊ិនធើណេសិនណល អ៊ិនស៊ីអេន ស្ថិតក្នុងភូមិអូរស្គាន សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋឈ្មោះ ម៉ី កែវមរកត




| No | X | Y | No | X | Y |
|---|---|---|---|---|---|
| 1 | 741568 | 1374171 | 28 | 741958 | 1374901 |
| 2 | 741415 | 1374577 | 29 | 742022 | 1374931 |
| 3 | 741468 | 1374595 | 30 | 742058 | 1374947 |
| 4 | 741495 | 1374612 | 31 | 742095 | 1374956 |
| 5 | 741504 | 1374644 | 32 | 742166 | 1374978 |
| 6 | 741489 | 1374679 | 33 | 742226 | 1374998 |
| 7 | 741450 | 1374705 | 34 | 742344 | 1375026 |
| 8 | 741405 | 1374690 | 35 | 742404 | 1375044 |
| 9 | 741383 | 1374684 | 36 | 742525 | 1375109 |
| 10 | 741366 | 1374730 | 37 | 742589 | 1375088 |
| 11 | 741367 | 1374744 | 38 | 742692 | 1375257 |
| 12 | 741374 | 1374754 | 39 | 742769 | 1375238 |
| 13 | 741464 | 1374823 | 40 | 742860 | 1375238 |
| 14 | 741530 | 1374843 | 41 | 742842 | 1375121 |
| 15 | 741566 | 1374857 | 42 | 742794 | 1375087 |
| 16 | 741610 | 1374871 | 43 | 742744 | 1375062 |
| 17 | 741650 | 1374886 | 44 | 742625 | 1375003 |
| 18 | 741674 | 1374894 | 45 | 742459 | 1374907 |
| 19 | 741693 | 1374895 | 46 | 742444 | 1374833 |
| 20 | 741711 | 1374894 | 47 | 742286 | 1374769 |
| 21 | 741736 | 1374886 | 48 | 742145 | 1374710 |
| 22 | 741758 | 1374875 | 49 | 742025 | 1374659 |
| 23 | 741779 | 1374867 | 50 | 741960 | 1374633 |
| 24 | 741803 | 1374860 | 51 | 741916 | 1374619 |
| 25 | 741837 | 1374857 | 52 | 741845 | 1374211 |
| 26 | 741870 | 1374860 | 53 | 741663 | 1374183 |
| 27 | 741909 | 1374873 | | | |